**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០៩៤ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០ ១៦

# ប្រកាស

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលទ្រទ្រង់ "China Ready" សម្រាប់ទេសចរណ៍កម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ មិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញប្រកាសលេខ០៤០ ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍នៃអគ្គនាយកដ្ឋានទេសចណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើត “**មជ្ឈមណ្ឌលទ្រទ្រង់** China Ready ***សម្រាប់ទេសចរណ៍កម្ពុជា***” ដែលមានឈ្មោះជាភាសាអង់គ្លេស “China Ready Center” ដែលសរសេរជាអក្សរកាត់ថា “CRC” ដើម្បីចាត់ចែងដាក់ឱ្យអនុវត្តនូវសៀវភៅ**ស** ស្តីពី “China Ready” សម្រាប់ទេសចរណ៍កម្ពុជា ឱ្យមានប្រសិទ្ធភាព និងគុណភាព។

**ប្រការ ២._**

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជា មានបេសកកម្មផ្តល់ការប្រឹក្សាយោបល់លើការវិនិយោគទេសចរណ៍ ការអភិវឌ្ឍផលិតផលទេសចរណ៍ អប់រំបណ្តុះបណ្តាល ពង្រឹងសមត្ថភាពភាសាចិន វប្បធម៌នៃទេសចរជនជាតិចិន សិក្សាស្រាវជ្រាវ វិភាគទីផ្សារទេសចរណ៍ចិន និងការផ្តល់នូវប្រព័ន្ធវាយតម្លៃបញ្ជាក់គុណភាព China-Ready Accreditation សម្រាប់ឧស្សាហកម្មទេសចរណ៍កម្ពុជា សំដៅផ្តល់នូវសេវាប្រកបដោយគុណភាពឆ្លើយតបនឹងសេចក្តីត្រូវការរបស់ទេសចរចិន។

**ប្រការ ៣._**

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជាមានតួនាទី និងភារកិច្ចអនុវត្តការងារដូចខាងក្រោម៖

- ដាក់អនុវត្តសៀវភៅ**ស** ស្តីពី “China Ready” សម្រាប់ទេសចរណ៍កម្ពុជា (ដូចមានក្នុងឧបសម្ព័ន្ធទី១)
- បណ្តុះបណ្តាលជំនាញពាក់ព័ន្ធ និងភាសាចិនដល់ប្រតិបត្តិករទេសចរណ៍
- សិក្សាស្រាវជ្រាវ និងវិភាគពីទីផ្សារទេសចរចិន
- ផ្តល់សេវាប្រឹក្សាយោបល់ផ្នែកធុរកិច្ច និងវិនិយោគសម្រាប់ទីផ្សារចិន
- រៀបចំ និងអនុវត្តស្តង់ដាវាយតម្លៃរបស់កម្ពុជាសម្រាប់ សេវាកម្មទេសចរណ៍ត្រៀមទទួលភ្ញៀវទេសចរចិន China Ready Accreditation (ដូចមានក្នុងឧបសម្ព័ន្ធទី២)
- ទទួលអនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងទេសចរណ៍ប្រគល់ជូន។

**ប្រការ ៤._**

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជា គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពជាក់ស្តែងកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជា អាចទទួលយកទីប្រឹក្សាបច្ចេកទេសអ្នកជំនាញការជាតិ ឬអន្តរជាតិមួយចំនួនតាមការចាំបាច់។

**ប្រការ ៥._**

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានទេសចរណ៍ក្នុងដំណើរការការងាររបស់ខ្លួន។

**ប្រការ ៦._**

មជ្ឈមណ្ឌលទ្រទ្រង់ “China Ready” សម្រាប់ទេសចរណ៍កម្ពុជា មានកញ្ចប់ថវិកាជាឧបសម្ព័ន្ធក្នុងកម្មវិធីថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធិភាព។

**ប្រការ ៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានក្រុមអ្នកច្បាប់ អធិការ ប្រធានគ្រប់នាយកដ្ឋាន និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលអនុវត្តតាមស្មារតីប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានកំណែទំរង់រដ្ឋបាល
- សហព័ន្ធទេសចរណ៍កម្ពុជា (CTF)
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ